**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកែប**
សំណុំរឿងព្រហ្មទណ្ឌលេខ ៣០
ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣
សាលក្រមលេខ ២៦ "ឃ"
ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកែប

បានបើកសវនាការពិភាក្សាដេញដោលចំពោះមុខជាសាធារណៈ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងប្រាំបី និង សាមសិប នាទីព្រឹក

ដោយមានសមាសភាពដូចខាងក្រោម៖

**សមាសភាពជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកែប

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកែប

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកែប

**តុលាការ**

-**បានឃើញ**: ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ១៩ អ.យ.ខ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកែប។

-**បានឃើញ**: ដីកាសន្និដ្ឋានស្ថាពរលេខៈ ២៤ អ.យ.ខ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកែប។

-**បានឃើញ**: ដីកាដំណោះស្រាយលេខៈ ២៧/២៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកែប។

-**បានឃើញ**: ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកែប។

-**បានឃើញ**: ដីកាសម្រេចដាក់រឿងជំនុំជម្រះ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកែប។

-**បានឃើញ**: ការផ្តល់ដំណឹងពីកាលបរិច្ឆេទនៃសវនាការតាមមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ ៣០ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣ ដែលមាន៖



Scanned with CamScanner

## ជនជាប់ចោទ

ឈ្មោះ [redacted] សុភារិទ្ធិ ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរមន្ត្រីរាជការ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ចាន់ថុន "រ" ម្តាយឈ្មោះ [redacted] ចាន់នី "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន ។

ជាប់ចោទពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចខាងជើងស្ពានបាក់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០២៣ វេលាម៉ោង២០ និង៣០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីនៃក្រុមមេធាវី អេលីត (ELITE LAY GROUP) ទីតាំងស្ថិតនៅផ្ទះលេខ២៩ ផ្លូវ P04 ក្នុងបុរីប៉េងហួតដឹស្តារព្រី-មៀរ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

## ដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] **ប៊ុនណារី** ហៅ ម៉ៅ ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ មេផ្ទះ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតស្ថិតនៅសង្កាត់ចាក់អង្រែ ខណ្ឌមានជ័យ រាជធានីភ្នំពេញ អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ឪពុកឈ្មោះ [redacted] ទុយ "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] DONALD LYNN "ស" មានកូនចំនួន ០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុន "គ្មាន"។

## អង្គហេតុនៃបណ្តឹងចោទប្រកាន់

កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ២០ និង ៣០ នាទី មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើងរវាងរថយន្ត នឹងម៉ូតូ ដែលមានទិសដៅស្របគ្នានៅលើកំណាត់ផ្លូវជាតិលេខ ៣៣អា ចន្លោះបង្គោលគីឡូម៉ែត្រលេខ ១២ និង ១៣ ត្រង់ចំណុចខាងជើងស្ពានបាក់ ចម្ងាយ ១៦ម៉ែត្រ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប បង្កដោយរថយន្តម៉ាក PRIUS (ព្រុស) ពណ៌ខៀវ ផលិតឆ្នាំ២០០៥ ពាក់ស្លាកលេខ ភ្នំពេញ 2BA-5065 បើកបរពីត្បូងទៅជើង ដោយឈ្មោះ [redacted] សុភារិទ្ធិ ភេទប្រុស បើកមកដល់ចំណុចកើតហេតុ ក៏បានបុកជាម៉ូតូមួយគ្រឿងម៉ាក TODAY (ធូដេ) ពណ៌ខៀវ គ្មានស្លាកលេខ គ្មានភ្លើងបំភ្លឺពីខាងក្រោយ ឬចំណាំងផ្លាតជាសញ្ញា បើកដោយឈ្មោះ [redacted] DONALD LYNN ([redacted] ដូណាល លីន) ភេទប្រុស អាយុ ៦១ឆ្នាំ មុខរបរ ទេសចរណ៍ ជនជាតិអាមេរិកកាំង ស្លាប់នៅកន្លែងកើតហេតុ។

## នាពេលសវនាការ

កិច្ចជំនុំជម្រះបានចាប់ផ្តើម ដោយចៅក្រមជំនុំជម្រះបានប្រកាសបើកសវនាការ និងបានឲ្យក្រឡាបញ្ជីធ្វើការរាយការណ៍អំពីវត្តមានចូលរួមរបស់ភាគី និងសាកសួរយោបល់របស់តំណាងអយ្យការ អំពីដំណើររឿងក្តីបន្ត។ ជាយោបល់របស់តំណាងអយ្យការ បានផ្តល់យោបល់ និងស្នើសុំថា ខ្លួនសុំឲ្យមានការជំនុំជម្រះលើរឿងក្តីនេះ ចៅក្រមជំនុំជម្រះក៏បានប្រាប់ជនជាប់ចោទពីបទចោទប្រកាន់ និងបានប្រាប់អំពីសិទ្ធិរបស់ជនជាប់ចោទ ដើម្បីការពារខ្លួននាពេលជំនុំជម្រះ ៖



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ បានឆ្លើយថាៈ ខ្លួនទទួលស្គាល់បទចោទប្រកាន់របស់តំណាងអយ្យ-ការ។ ខ្លួនបានដឹងពីកំហុសហើយ។ ហើយរូបខ្លួនក៏បានសងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងរួចហើយ។ ខ្លួនស្នើសុំតុលាការសម្រេចលើកលែងទោសដល់ខ្លួនផង។

-អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ប៊ុនណារី ហៅ ម៉ៅ នៅដំណាក់កាលចៅក្រមស៊ើបសួរថាៈ ខ្លួនត្រូវជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ [redacted] DONLD LYNN ([redacted] ដូណាល លីន) ជនជាតិអាមេរិក ដែលបានស្លាប់ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ៨យប់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ។ នៅមុនពេលកើតហេតុ វេលាម៉ោងជិត ០៨យប់ ប្តីរបស់ខ្លួនបានប្រាប់ខ្លួនថាទៅទិញអីហូប ដោយគាត់បានជិះម៉ូតូម៉ាក ធូរេ ពណ៌ខៀវ គ្មានផ្លាកលេខ បើកតែម្នាក់ឯងមិនបាន ពាក់មួកសុវត្ថិភាព អស់រយៈពេលមួយសន្ទុះធំ ក៏មិនទាន់ឃើញគាត់ត្រឡប់មកផ្ទះវិញ ស្រាប់តែបន្តិចក្រោយមក មានគេទូរស័ព្ទមកប្រាប់ខ្លួនថា ប្តីខ្លួនបានជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប់បាត់ហើយ នៅមុំផ្លូវស្ពានបាក់ ពេលនោះ ខ្លួនក៏បានដើរចេញមកក្រៅមើលនៅលើថ្នល់ពុំឃើញមានអ្វីនោះទេ។ លុះព្រឹកឡើង ខ្លួនបានទទួលដំណឹងថា សពរបស់ប្តីខ្លួនត្រូវគេយកទៅដំកល់នៅមន្ទីរពេទ្យបង្អែកខេត្តកែបបាត់ហើយ។ ខ្លួនសុំដកពាក្យបណ្តឹងមិនប្តឹងតទៅទៀតទេ ព្រោះសុទ្ធតែជាជនរងគ្រោះដូចគ្នា ខាងអ្នកបើកបរថយន្ត គាត់ក៏បានមកចូលរួមបុណ្យជាថវិកា មួយចំនួនរួចរាល់ផងដែរ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយកិច្ចពិភាក្សាដេញដោលនាពេលសវនាការ បង្ហាញឲ្យឃើញថាៈ ក្រោយស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ព្រមទាំងបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង៣០នាទី យប់ មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ពិតប្រាកដមែន។ ដូច្នេះតំណាងអយ្យការនៅតែរក្សាតម្កល់ដីកាសន្និដ្ឋានស្ថាពរ ២៤ អ.យ.ខ/២៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ ទុកដដែល ក៏ប៉ុន្តែតំណាងអយ្យការស្នើសុំតុលាការសម្រេចបន្ធូរបន្ថយទោសដល់ជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ ដោយជននេះបានដឹងពីកំហុស និងបានសងសំណងទៅដើមបណ្តឹង ម្យ៉ាងទៀតដើមបណ្តឹងក៏បានដាក់ពាក្យសុំ ដកពាក្យបណ្តឹងវិញកាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ រួចហើយផងដែរ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយកិច្ចពិភាក្សាដេញដោលនាពេលសវនាការ បន្ទាប់ពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទរួចមកៈ ខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ សូមស្នើសុំតុលាការសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន ព្រោះកូនក្តីរបស់ខ្លួន គាត់បានដឹងពីកំហុស និងបានសងសំណងទៅដើមបណ្តឹងរួចហើយ ម្យ៉ាងទៀតដើមបណ្តឹងក៏បានដាក់ពាក្យសុំដកពាក្យបណ្តឹងវិញដែរ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសូមស្នើសុំតុលាការសម្រេចបន្ធូរបន្ថយទោស។

## សម្តីចុងក្រោយការពារខ្លួន និងសំណូមពររបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ ស្នើសុំតុលាការបន្ធូរបន្ថយទោស ព្រោះខ្ញុំបានដឹងពីកំហុសហើយ។

## សាលាដំបូង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី



Scanned with CamScanner

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងពាក់ព័ន្ធនានា ក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ

-ក្រោយពីបានពិនិត្យយ៉ាងល្អិតល្អន់ និងពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយ

## សំអាងហេតុ

តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលចំពោះមុខជាសាធារណៈ ដើម្បីស្វែងរកការពិតនៃសំណុំរឿងក្ដីព្រហ្មទណ្ឌនេះ តាមរយៈការស្ដាប់ចម្លើយរបស់ភាគីទាំងឡាយដែលពាក់ព័ន្ធ និងការពិនិត្យភស្តុតាងដែលបានស្វែងរកដោយមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ តុលាការយល់ឃើញថា៖

**១.បណ្ដឹងចោទប្រកាន់**

តំណាងអយ្យការ និងចៅក្រមស៊ើបសួរ បានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើជនជាប់ចោទ៖

-ឈ្មោះ [redacted] សុភារិទ្ធិ ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឲ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចខាងជើងស្ពានបាក់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ២០ និង ៣០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

**២.ការវិនិច្ឆ័យចំពោះបទចោទប្រកាន់**

-តាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក បានចែងថា ៖

ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកិច្ចដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្ដាលឲ្យស្លាប់ដល់អ្នកដទៃ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០ ៛ (បួនលាន) រៀល ទៅ ១៥,០០០,០០០៛ (ដប់ប្រាំលាន) រៀល និងអាចត្រូវផ្ដន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា៥៣ នៃក្រមព្រហ្មទណ្ឌ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ បានឆ្លើយសារភាពថា៖ ខ្លួនទទួលស្គាល់បទចោទប្រកាន់របស់តំណាងអយ្យការ។ ខ្លួនបានដឹងពីកំហុសហើយ។ ហើយរូបខ្លួនក៏បានសងសំណងរដ្ឋប្បវេណីទៅដើមបណ្ដឹងរដ្ឋប្បវេណីរួចហើយ។ ខ្លួនស្នើសុំតុលាការសម្រេចលើកលែងទោសដល់ខ្លួនផង។

-តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនណារី ហៅ ម៉ៅ នៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនត្រូវជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ [redacted] DONLD LYNN ([redacted] ដូណាល លីន) ជនជាតិអាមេរិក ដែលបានស្លាប់ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង៨យប់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ។ នៅមុនពេលកើតហេតុ វេលាម៉ោងជិត០៨យប់ ប្ដីរបស់ខ្លួនបានប្រាប់ខ្លួនថាទៅទិញអីហូប ដោយគាត់បានជិះម៉ូតូម៉ាក ធូដេ ពណ៌ខៀវ គ្មានផ្លាកលេខ បើកតែម្នាក់ឯង មិនបានពាក់មួកសុវត្ថិភាព អស់រយៈពេលមួយសន្ទុះធំ ក៏មិនទាន់ឃើញគាត់ត្រឡប់មកផ្ទះវិញ ស្រាប់តែបន្តិចក្រោយមក មានគេទូរស័ព្ទមកប្រាប់ខ្លួនថា ប្ដីខ្លួនបានជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប់បាត់ហើយ នៅម្ដុំផ្លូវស្ពានបាក់ ពេលនោះខ្លួនក៏បានដើរចេញមកក្រៅមើលនៅលើថ្នល់ពុំឃើញមានអ្វីនោះទេ។ លុះព្រឹកឡើង ខ្លួនបានទទួលដំណឹងថា សពរបស់ប្ដីខ្លួនត្រូវគេយកទៅដាក់នៅមន្ទីរពេទ្យបង្អែកខេត្តកែបបាត់ហើយ។ ខ្លួនសុំដកពាក្យបណ្ដឹងមិនប្ដឹងតទៅទៀតទេ ព្រោះសុទ្ធតែជាជនរងគ្រោះដូចគ្នា ខាងអ្នកបើកបររថយន្តគាត់ក៏បានមកចូលរួមបុណ្យជាថវិកា មួយចំនួនរួចរាល់ផងដែរ។



Scanned with CamScanner

-យោងតាមរបាយការណ៍បញ្ជូនរបស់មន្ត្រីនគរបាលយុត្តិធម៌ ទទួលបន្ទុកចរាចរណ៍ រួមមាន៖

-កំណត់ហេតុត្រួតពិនិត្យជនរងគ្រោះថ្នាក់ចរាចរណ៍

-កំណត់ហេតុប្រគល់សាកសព

-កំណត់ហេតុត្រួតពិនិត្យកន្លែងកើតហេតុ

-កំណត់ហេតុចាប់យកវត្ថុតាង

-ស្លាកស្នាមខូចខាតយានយន្តដោយគ្រោះថ្នាក់ចរាចរណ៍

-គំរោងដើមនៃគ្រោះថ្នាក់ចរាចរណ៍

-គំនូសស្នាមនៃគ្រោះថ្នាក់ចរាចរណ៍

-លិខិតមរណភាព និង

-រូបថតជនរងគ្រោះ

ឃើញថា៖ តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គឺមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងនានាខាងលើ ដែលបង្ហាញឲ្យឃើញថា៖ ជនជាប់ចោទពិតជាបានបើកបររថយន្តដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងបណ្តាលឲ្យជនរងគ្រោះឈ្មោះ [redacted] DO NLD LYNN [redacted] ដូណាល លីន ) ជនជាតិអាមេរិក ស្លាប់នៅចំណុចខាងជើងស្ពានបាក់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ប្រាកដមែន ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ពីបទ: **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចខាងជើងស្ពានបាក់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង២០ និង៣០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

### ៣.ការវិនិច្ឆ័យចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំ

-តំណាងអយ្យការប្តឹងសុំទៅក្រុមជំនុំជម្រះ សម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំតុលាការសម្រេចបន្ធូរបន្ថយទោស ។

-តាមបញ្ញត្តិមាត្រា ៣៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា៖ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការមានមូលដ្ឋានត្រឹមត្រូវសមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌ គប្បីតុលាការពិចារណាតាមច្បាប់ ។

-ការស្នើសុំបន្ធូរបន្ថយទោសរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងកំណត់សម្គាល់របស់ជនជាប់ចោទខាងលើ គប្បីតុលាការ ទទួលយកមកពិចារណា តាមនីតិវិធីច្បាប់ជាធរមាន។

### ៤.ការវិនិច្ឆ័យចំពោះសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ

ជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ គឺជានីតិជនដែលមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ពោលគឺពុំមានភស្តុតាងណាមួយបញ្ជាក់ថាជននេះមានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទ ពិតជាមានស្មារតីយល់ដឹងអំពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ស្របតាមបញ្ញត្តិមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។



Scanned with CamScanner

### ៥.ការវិនិច្ឆ័យចំពោះទោស និងរបបប្រកាសទោស

#### ក.ចំពោះទោស

តុលាការពិចារណាលើការសម្រេចទោសទៅលើជនជាប់ចោទ ដោយផ្អែកលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ មុន អំឡុងពេល និងក្រោយប្រព្រឹត្តអំពើល្មើស ដោយហេតុថាជនជាប់ចោទមានការភ្ញាក់រលឹកនូវអំពើរបស់ខ្លួន និងសន្យាក្នុងការកែប្រែកំហុសមិនឲ្យកើតមានការធ្វេសប្រហែសម្តងទៀតទេ ។ គប្បី តុលាការពិចារណាទៅលើការផ្តន្ទាទោសលើជនជាប់ចោទក្នុងព្រំដែននៃទោសជាអប្បបរមា តាមបញ្ញត្តិមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៃព្រះរាជាណាចក្រកម្ពុជា ជាធរមាន ។

#### ខ.ចំពោះរបបប្រកាសទោស

-តាមបញ្ញត្តិមាត្រា៩៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៃព្រះរាជាណាចក្រកម្ពុជា តុលាការសម្រេចយកការប្រកាសមូលទោស ដោយការផ្តន្ទាទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះទៅលើជនជាប់ចោទខាងលើ ដោយហេតុថា ជនជាប់ចោទពុំមានលទ្ធភាពក្នុងការបង់ប្រាក់ពិន័យចូលជាថវិការដ្ឋ នោះឡើយ ។ម៉្យាងទៀត ជនជាប់ចោទក៏ត្រូវទទួលខុសត្រូវលើផ្នែកសំណងរដ្ឋប្បវេណី ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ផងដែរ ។

-យោងទៅតាមស្ថានភាពជាក់ស្តែងនៃការប្រព្រឹត្តបទល្មើស ឃើញថា គ្រោះថ្នាក់ចរាចរណ៍គឺពុំមាននរណាម្នាក់មានចេតនាចង់ឲ្យកើតឡើងនោះទេ ពោលគឺកើតចេញអំពីការធ្វេសប្រហែស ខ្ជីខ្ជា និងមិនប្រុងប្រយ័ត្នមួយពេល ដូច្នេះ គប្បីតុលាការពិចារណាលើកយករបបនៃការប្រកាសទោសដោយធ្វើការព្យួរការអនុវត្តទោសធម្មតាទាំងស្រុង ទៅលើមូលទោសដែលបានប្រកាសទៅលើជនជាប់ចោទ តាមបញ្ញត្តិមាត្រា ១០៤ ដល់មាត្រា ១១១ នៃក្រមព្រហ្មទណ្ឌ ។

### ៦.ការវិនិច្ឆ័យចំពោះវត្ថុចាប់យក

-វត្ថុចាប់យក ដែលត្រូវបានដកហូតដោយមន្ត្រីនគរបាលយុត្តិធម៌ រួមមាន:

១.រថយន្តមួយគ្រឿងម៉ាក TOYOTA PRIUS (ព្រុស) ពណ៌ខៀវ ពាក់ស្លាកលេខភ្នំពេញ 2BA-5065 ផលិតឆ្នាំ២០០៥ ។

-យោងតាមដីកាសម្រេចប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញលេខ១៣៣/២៣ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកែប (រថយន្ត) វត្ថុចាប់យកខាងលើនេះត្រូវបានចៅក្រមស៊ើបសួរប្រគល់ឲ្យម្ចាស់ដើមវិញរួចរាល់ គប្បីតុលាការមិនលើកយកមកពិចារណា និងសម្រេចនោះឡើយ។

២.ម៉ូតូមួយគ្រឿងម៉ាកធូដេ ពណ៌ខៀវ គ្មានស្លាកលេខ ដូចមានក្នុងកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ ។ ដោយហេតុថា អត្តសញ្ញាណនៃចលនវត្ថុជាម៉ូតូខាងលើ គឺមានភាពមិនច្បាស់លាស់ ព្រមទាំងពុំមានប័ណ្ណសម្គាល់យានជំនិះ និងផ្លាកលេខត្រឹមត្រូវតាមច្បាប់នោះឡើយ ។ គប្បីតុលាការមិនលើកយកមកពិចារណា និងសម្រេចបាន នោះឡើយ។

### ៧.ការវិនិច្ឆ័យចំពោះសំណងរដ្ឋប្បវេណី

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនណារី ហៅ ម៉ៅ បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំបានទាមទារសំណងរដ្ឋប្បវេណីនោះទេ ព្រោះដើមបណ្តឹងរដ្ឋប្បវេណីបានទទួលសំណងរួចហើយ ។ ហេតុដូច្នេះ គប្បីតុលាការមិនលើកយកមកសម្រេចជាថ្មីនោះទេ។



Scanned with CamScanner

## **វិនិច្ឆ័យសេចក្តី**

## **ហេតុដូច្នេះសម្រេច**

-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ (មានអត្ត-សញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ)ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរការអនុវត្តទោសជម្មតាទាំងស្រុង ។

ពីបទ: **បើកបរដោយធ្វេសប្រហែល ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យស្លាប់អ្នកដំទៃ** ប្រព្រឹត្តនៅចំណុចខាងជើងស្ពានបាក់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង២០ និង៣០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនណារី ហៅ ម៉ៅ និងចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុភារិទ្ធិ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

ហត្ថលេខានិងត្រា- [redacted] | ហត្ថលេខានិងត្រា, [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ១រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ខេត្តកែប ,ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]